**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ : ២៥៣ សសរ

ក្រុមជំនួយការឯកឧត្តម [illegible]

ទទួល ថ្ងៃទី ៤ ខែ ០៤ ឆ្នាំ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧

ក្រសួងមហាផ្ទៃ

ចូល ៦៦១ 03.04.2017

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**គោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**<u>កម្មវត្ថុ:</u>** ករណីសំណើសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឱ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស ។

**<u>យោង:</u>** -លិខិតលេខ ៤១៥ ល.ស ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ

-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៧ ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមគោរពជម្រាបជូនសម្តេចក្រឡាហោមមេត្តាជ្រាបថា ចំពោះសំណើរបស់ក្រសួងមហាផ្ទៃដែលបានស្នើសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឱ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេសនោះ រាជរដ្ឋាភិបាលបានសម្រេច ក្នុងពេលរង់ចាំការរៀបចំ និងអនុម័តច្បាប់ស្តីពីការពពោះ ការដោះស្រាយបញ្ហាចំពោះមុខត្រូវផ្អែកលើគោលការណ៍ចម្បងដូចខាងក្រោម ៖

(ទី១) ជានានូវការអនុវត្តតួនាទីរបស់អាជ្ញាធររដ្ឋក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋខ្លួន ជាពិសេសលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកុំឱ្យកម្ពុជាក្លាយជាគោលដៅនៃការធ្វើអាជីវកម្មពពោះជំនួស និង (ទី២) ធានាផលប្រយោជន៍របស់ទារកចេញដែលកកំណើត ឬដែលបានកើតមកហើយ ។ ផ្អែកលើគោលការណ៍នេះ ដំណោះស្រាយចំពោះបញ្ហាខាងលើ ក្នុងពេលចំពោះមុខត្រូវអនុវត្តទៅតាមច្បាប់ត្រឹមកម្រិត ច្បាប់ដែលយើងមានបច្ចុប្បន្ន និងដាក់ចេញផែនការរឹតបន្តឹងមួយចំនួនដូចខាងក្រោម:

<u>ផែនការទី១</u>- ការនាំយកទារកចេញទៅប្រទេសក្រៅអាចអនុញ្ញាតដើម្បីជាផលប្រយោជន៍សម្រាប់ទារក ប៉ុន្តែការនាំយកចេញនេះ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់រដ្ឋប្បវេណីរបស់កម្ពុជាគឺ៖

- ក្នុងករណីស្ត្រីពពោះមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ កូនដែលកើតមកត្រូវសន្មតថាជាកូនរបស់ប្តីនៃស្ត្រីពពោះ ។ ឪពុកដែលជាម្ចាស់មេជីវិតចាំបាច់ត្រូវប្តឹងទៅតុលាការដើម្បីទាមទារបិតុភាព(ភាពជាឪពុក)លើទារកនោះតាមផ្លូវច្បាប់ដោយបង្ហាញភស្តុតាងកោសល្យវិច្ច័យលើ DNA ។
- ក្នុងករណីស្ត្រីពពោះនៅលីវ ឬពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ឪពុកដែលជាម្ចាស់មេជីវិតត្រូវប្តឹងទៅតុលាការសុំសិទ្ធិគ្រប់គ្រងកូន ដើម្បីអាចនាំកូននោះទៅក្រៅប្រទេសកម្ពុជាបាន ។

ការសម្រេចអនុញ្ញាតនឹងអាចធ្វើបានដោយតុលាការ ប្រសិនស្ត្រីពពោះព្រមព្រៀងប្រគល់កូននោះឱ្យទៅឪពុកជាម្ចាស់មេជីវិតគ្រប់គ្រង ។ កិច្ចសន្យាពពោះមិនអាចយកមកធ្វើជាមូលដ្ឋានកំណត់ការព្រមព្រៀងនេះបានទេ ព្រោះជាកិច្ចសន្យាខុសច្បាប់ ។

- ដោយឡែក ចំពោះវិធានការព្រហ្មទណ្ឌ គឺនៅតែបន្តអនុវត្តចំពោះករណីជនល្មើសដែលជាអន្តរការីនៃការពពោះជំនួស ស្របតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ ។

<u>វិធានការទី២</u>- ដើម្បីទប់ស្កាត់ការកើតឡើងនូវករណីថ្មី និងការពារមិនឱ្យកម្ពុជាក្លាយជាគោលដៅនៃអាជីវកម្មជួញដូរទារក ដំណោះស្រាយនេះនឹងត្រូវបានកំណត់តែចំពោះទារកដែលមានកំណើតក្នុងផ្ទៃរួចហើយ គិតចាប់ពីថ្ងៃចេញផ្សាយគោលការណ៍នេះតទៅរហូតដល់រយៈពេល៩ខែ ១០ថ្ងៃក្រោយ ដើម្បីទុកឱកាសឱ្យទារកដែលមានកំណើតរួចហើយទទួលបានការការពារ ហើយទន្ទឹមនឹងនេះ ការចេញប្រកាសហាមឃាត់ការពពោះជំនួសគឺជាការចាំបាច់ អមដោយការរឹតបន្តឹងវិធានការរដ្ឋបាល ពិសេសការត្រួតពិនិត្យតាមគ្លីនិកមួយចំនួនដែលមានបច្ចេកវិទ្យាពាក់ព័ន្ធនឹងការពពោះ ។

<u>វិធានការទី៣</u>- ដើម្បីដោះស្រាយបញ្ហាការពពោះនេះឱ្យបានគ្រប់ជ្រុងជ្រោយ និងចប់សព្វគ្រប់ ត្រូវជំរុញការរៀបចំនិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងការពពោះជំនួស» ឱ្យបានឆាប់ ហើយរៀបចំច្បាប់នេះ ចាំបាច់ត្រូវសិក្សាឱ្យបានគ្រប់ទិដ្ឋភាពដែលដោះស្រាយយថាភាពនានា ដែលអាចកើតមានឡើងដោយសារភាពស្មុគស្មាញនៃបញ្ហា និងការវិវត្តកាន់តែជឿនលឿននូវបច្ចេកវិទ្យាក្នុងវិស័យនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

**ជ.រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ស៊ុ តិរិទ្ធ**

**<u>ចម្លងជូន:</u>**
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងយុត្តិធម៌
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ